May 24, 2019

# សមាជិកព្រឹទ្ធសភាស្នើច្បាប់ទាមទារដោះលែងលោកកឹម សុខានិងទម្លាក់ចោលការចោទប្រកាន់លោកសម រង្ស៊ី



រូបឯកសារ៖ សមាជិកព្រឹទ្ធសភាអាមេរិកលោក ឌីក ឌឺប៊ីន (Dick Durbin) និងលោក លីនស៊ី ហ្គ្រែម (Lindsey Graham) ថ្លែងក្នុងសន្និសីទសារព័ត៌មាននៅវិមាន Capital Hill ក្នុងរដ្ឋធានីវ៉ាស៊ីនតោន កាលពីថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៨។ (រូបថត AP)

**ម៉ែន គឹមសេង | VOA Khmer, 22 ឧសភា 2019**

*វ៉ាស៊ីនតោន — សមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិកបានស្នើច្បាប់ថ្មីមួយដែលទាមទារឱ្យដោះលែងនិងទម្លាក់ចោលការចោទប្រកាន់មេដឹកនាំគណបក្សសង្គ្រោះជាតិដែលកំពុងជាប់ឃុំឃាំងក្នុងលំនៅដ្ឋាននិងខ្លះកំពុងនិរទេសខ្លួននៅក្រៅប្រទេស។*

*សេចក្តីស្នើច្បាប់នេះហៅថា«ច្បាប់ស្តីពីការទទួលខុសត្រូវរបស់កម្ពុជានិងការវិលត្រឡប់វិញនូវការវិនិយោគ» ឆ្នាំ២០១៩ (ហៅកាត់ថា* CARI Act) *ត្រូវបានស្នើឡើងវិញជាថ្មីដោយសមាជិកព្រឹទ្ធសភាចំនួន៣រូបដែលមកពីគណបក្សទាំងពីរ គឺលោក លីនស៊ី ហ្គ្រែម* (Lindsey Graham) *លោក ឌីក ដឺប៊ីន* (Dick Durbin) *និងលោក ម៉ាកូ រូប៊ីអូ* (Marco Rubio) *កាលពីសប្តាហ៍មុន។ នេះបើតាមសេចក្តីចម្លងសេចក្តីស្នើច្បាប់ដែលវីអូអេទទួលបាននៅថ្ងៃអង្គារនេះ។*

*សេចក្តីស្នើច្បាប់*CARI Act *ទាមទារឱ្យដោះលែងលោកកឹម សុខា ពីការឃុំឃាំងក្នុងលំនៅដ្ឋានដោយឥតលក្ខខណ្ឌ*

ទម្លាក់ចោលបទចោទប្រកាន់ព្រហ្មទណ្ឌនានាប្រឆាំងនឹងលោក សម រង្ស៊ី និងអ្នកប្រឆាំងរដ្ឋាភិបាលជាច្រើនរូបទៀត ក្នុងនោះមានការទម្លាក់ការចោទប្រកាន់អតីតអ្នកសារព័ត៌មានវិទ្យុអាស៊ីសេរីចំនួនពីរនាក់ផងដែរ។

ដូចគ្នានឹងសេចក្តីស្នើច្បាប់CARI Act ដែលបានស្នើឡើងកាលពីដើមឆ្នាំ២០១៨ដែរ គឺច្បាប់នេះនឹងតម្រូវឱ្យបង្កកទ្រព្យសម្បត្តិមន្ត្រីរដ្ឋាភិបាលកម្ពុជាដែលមានទ្រព្យធនរក្សាទុកនៅសហរដ្ឋអាមេរិកនិងក៏ទាមទារឱ្យសហរដ្ឋអាមេរិកប្រឆាំងជំទាស់រាល់ប្រាក់កម្ចីទៅប្រទេសកម្ពុជាផងដែរ។

បើចូលជាធរមានច្បាប់នេះក៏នឹងតម្រូវឱ្យប្រទេសកម្ពុជា«ការពារអធិបតេយ្យខ្លួនពីការចូលជ្រៀតជ្រែក» ពីប្រទេសកុម្មុយនិស្តចិនផងដែរ៕